# អំពើហិង្សាលើកុមារនៅប្រទេសកម្ពុជា

## ការប្តេជ្ញាចិត្តដើម្បីបង្ការ និងឆ្លើយតប
## នឹងអំពើហិង្សាលើកុមារនៅកម្ពុជា



ការពារ
កុមារ
របស់យើង
នៅកម្ពុជា

**រចនាគម្របសៀវភៅដោយ៖** © Zoom in Projects/២០១៩/ល្វីស បារ៉ែតតូ

**រចនា និងកាច់ទំព័រដោយ៖** © យូនីសេហ្វកម្ពុជា/២០១៩/សៀម យ៉ូរ៉ា

# ទាំងអស់គ្នា យើងអាចបញ្ចប់អំពើហិង្សាលើកុមារ

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលដើម្បីបង្ការ និងឆ្លើយតបនឹងអំពើហិង្សាលើកុមារ និងឈានទៅរៀបចំផែនការសកម្មភាពជាតិស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា។

បង្ហាញដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងឱកាសនៃពិធីប្រកាសផ្សព្វផ្សាយរបកគំហើញ នៃការសិក្សាស្រាវជ្រាវថ្នាក់ជាតិជុំវិញបញ្ហាអំពើហិង្សាលើកុមារ ឆ្នាំ២០១៣។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រសួងកិច្ចការនារី

## ក្រសួងនឹងអំពាវនាវមិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់រូបភាព

1. ក្រសួងកិច្ចការនារីនឹងដឹកនាំការអភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថសង្គមជាពហុវិស័យគ្រប់ជ្រុងជ្រោយមួយ ដើម្បីឆ្លើយតបទៅនឹងនិយាមបទដ្ឋានសង្គម និងវប្បធម៌ ដែលផ្តល់កិច្ចការពារស្របច្បាប់ និងលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើកុមារដោយកំណត់គោលដៅទៅលើតួអង្គសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានចំពោះផ្នត់គំនិត ឥរិយាបថ និងការប្រព្រឹត្ត ព្រមទាំងការបង្កើនលទ្ធភាពរបស់ប្រជាពលរដ្ឋ ក្នុងការកំណត់អត្តសញ្ញាណ និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់អវិជ្ជមាននៃអំពើហិង្សាលើកុមារ។
2. ក្រសួងនឹងចូលរួមជាមួយកម្មវិធីអប់រំមាតាបិតា និងគ្រួសារ និងអប់រំកុមារបែបវិជ្ជមាន ដើម្បីលើកកម្ពស់ភាពអហិង្សាក្នុងការដាក់ពិន័យ និងទណ្ឌកម្មលើកុមារ ព្រមទាំងគាំពារកុមារឲ្យជៀសផុតពីហិង្សា និងអំពើរំលោភបំពាននានា។
3. ក្រសួងនឹងសម្របសម្រួលឱ្យមានការរៀបចំយុទ្ធសាស្ត្រ ក្នុងការទំនាក់ទំនងគ្រប់ជ្រុងជ្រោយមួយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សមភាព និងសមធម៌យេនឌ័រ សំដៅកាត់បន្ថយអំពើហិង្សាលើស្ត្រី និងកុមារ។ ក្រសួងនឹងលើកកម្ពស់ឱ្យមានគំរូវិជ្ជមានរបស់បុរស និងកម្មវិធីនានា ដែលផ្តល់ចំណេះដឹងស្តីពីវិធីសាស្ត្រក្នុងការបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ ជាពិសេសការរំលោភបំពានផ្លូវភេទ។
4. ក្រសួងនឹងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើឱ្យប្រសើរឡើងនូវជំនាញក្នុងការប្រាស្រ័យទាក់ទង ការដោះស្រាយបញ្ហា ការដោះស្រាយជម្លោះតាមបែបអហិង្សា និងជំនាញបំណិនជីវិត ក្នុងចំណោមកុមារ និងមនុស្សវ័យក្មេងប្រកបដោយសមធម៌យេនឌ័រ។
5. ក្រសួងនឹងរៀបចំ និងពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈអំពីកិច្ចការពារកុមារ សម្រាប់ភ្នាក់ងារនគរបាលយុត្តិធម៌ដើម្បីធានាថា ភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ទទួលបានការបណ្តុះបណ្តាល និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ហើយនឹងជំរុញឲ្យមានការដាក់ពិន័យ និងទណ្ឌកម្មទៅលើមន្ត្រីដែលប្រព្រឹត្តបទល្មើស ជាពិសេស អំពើហិង្សាផ្លូវភេទលើកុមារ និងមនុស្សវ័យក្មេង។
6. ក្រសួងនឹងបង្កើនចំនួនភ្នាក់ងារនគរបាលយុត្តិធម៌នៅកម្រិតថ្នាក់ស្រុក ព្រមទាំងលើកកម្ពស់សមត្ថភាព និងជំនាញក្នុងការគ្រប់គ្រងករណី និងការផ្តល់ការប្រឹក្សាយោបល់បឋម ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះករណីអំពើហិង្សាលើកុមារ និងមនុស្សវ័យក្មេង។
7. ក្រសួងនឹងបន្តលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ រាប់បញ្ចូលទាំងការស្វែងរកការគាំទ្រមតិឲ្យមានការរៀបចំលិខិតបទដ្ឋានគតិយុត្តិនានា សម្រាប់អនុវត្តច្បាប់នេះដើម្បីបង្កលក្ខណៈឱ្យមន្ត្រីឃុំសង្កាត់និងភូមិអាចធ្វើសកម្មភាពការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារបានកាន់តែមានប្រសិទ្ធភាព។
8. ក្រសួងនឹងសម្របសម្រួលដើម្បីអភិវឌ្ឍផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារដោយមានកិច្ចសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។
9. ក្រសួងនឹងដឹកនាំការសម្របសម្រួលឱ្យមានការពង្រឹង និងការធ្វើសុខដុមនីយកម្មការឆ្លើយតបរបស់សង្គមស៊ីវិលចំពោះអំពើហិង្សាលើកុមារ ដោយបំពេញបន្ថែមទៅលើគំនិតផ្តួចផ្តើម ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល។
10. ក្រសួងនឹងដាក់បញ្ចូលសូចនាករស្តីពីអំពើហិង្សាលើកុមារ ទៅក្នុងប្រព័ន្ធប្រមូល និងតាមដានទិន្នន័យអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលនឹងត្រូវបង្កើតឡើង ដើម្បីត្រួតពិនិត្យ និងវាយតម្លៃ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី២។

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ក្រសួងនឹងអំពាវនាវមិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់រូបភាព

1. ដោយមានកិច្ចសហការជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងគាំទ្រដល់ការបង្កើត និងការអនុវត្តយុទ្ធសាស្ត្រនៃការផ្លាស់ប្តូរ ការប្រព្រឹត្ត និងផ្លាស់ប្តូរសង្គមពហុវិស័យគ្រប់ជ្រុងជ្រោយមួយ ដើម្បីលើកកម្ពស់និយាមបទដ្ឋានសង្គមនិងវប្បធម៌ដែលផ្តល់នូវមនោសញ្ចេតនាអាណិតស្រឡាញ់និងលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើកុមារ ដោយកំណត់គោលដៅទៅលើតួអង្គសំខាន់ៗ នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិព្រមទាំងកំណត់ឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានចំពោះការគិត ឥរិយាបថ និងការអនុវត្ត។ នេះនឹងបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងការកំណត់អត្តសញ្ញាណអំពើហិង្សាលើកុមារ ការលើកកម្ពស់ការយល់ដឹងចំពោះផលប៉ះពាល់អវិជ្ជមាននៃអំពើហិង្សាការផ្តល់ភាពក្លាហានដល់កុមារ និងគ្រួសារ ក្នុងការរាយការណ៍អំពីឧបទ្ទវហេតុអំពើហិង្សា និងការរំលោភបំពាននានា។

2. ក្រសួងនឹងរួមចំណែកក្នុងការសម្របសម្រួល និងធ្វើសុខដុមនីយកម្មទៅលើបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ ដែលមានស្រាប់ សម្រាប់ឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ដើម្បីធានាថាបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ទាំងនោះមានដំណើរការពេញលេញ និងងាយស្រួលប្រើប្រាស់សម្រាប់កុមារ និងគ្រួសារ ដែលមានបំណងចង់រាយការណ៍អំពីឧបទ្ទវហេតុនៃអំពើហិង្សា និងការរំលោភបំពាន។

3. ក្រសួងនឹងបង្កើត ព្រមទាំងអនុវត្តយន្តការបណ្តឹង រាយការណ៍ និងបញ្ជូលករណីរំលោភបំពានលើកុមារ ដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ សម្រាប់កុមារគ្រប់រូប ដែលត្រូវបានបំបែកពីគ្រួសារបង្កើត សាច់ញាតិឱ្យទៅរស់នៅក្នុងមណ្ឌល ឬស្ថិតក្រោមការថែទាំដោយឪពុកម្តាយចិញ្ចឹម ឬការទុកដាក់ក្នុងការថែទាំជំនួសដទៃទៀត ក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយធានានូវសុវត្ថិភាព ឯកជនភាព និងរក្សាការសម្ងាត់ព្រមទាំងការសហការជាមួយនគរបាល និងតួអង្គសំខាន់ៗដទៃទៀត ដើម្បីឱ្យមានការថែទាំ ការព្យាបាល និងការតាមដានសមស្របចំពោះករណីរំលោភបំពាន។ ក្រសួងនឹងធានាថាកុមារ ជាពិសេសកុមារីត្រូវបានផ្តល់ការលើកទឹកចិត្តឱ្យហ៊ាននិយាយអំពីការរំលោភបំពានទៅលើសិទ្ធិរបស់ខ្លួន និងរាយការណ៍អំពីអំពើហិង្សា និងការរំលោភបំពានផ្លូវភេទ និងរាងកាយ។

4. ក្រសួងនឹងរៀបចំមូលដ្ឋានសម្រាប់ប្រព័ន្ធរាយការណ៍ បញ្ជូន និងឆ្លើយតបពហុវិស័យមួយ ដែលមានការសម្របសម្រួល និងត្រូវបានធ្វើសមាហរណកម្ម នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំពោះបញ្ហាការរំលោភបំពាន និងអំពើហិង្សាលើកុមារជាពិសេស ការរំលោភបំពានផ្លូវភេទកុមារនៅតាមវិស័យពាក់ព័ន្ធនានា។ ក្រសួងនឹងសម្របសម្រួលឱ្យមានការអភិវឌ្ឍនីតិវិធីកុមារមេត្រី និងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើយេនឌ័រ ដែលមានបទដ្ឋានប្រតិបត្តិ គោលការណ៍ណែនាំ និងបទដ្ឋានអប្បបរមា សម្រាប់ឆ្លើយតបទៅនឹងករណីអំពើហិង្សាលើកុមារ។ ក្រសួងនឹងធ្វើការងារជាមួយតួអង្គពាក់ព័ន្ធដើម្បីធានាថាបុគ្គលិកជួរមុខដែលទទួលបន្ទុកការងារការពារកុមារនិងមន្ត្រីមានសមត្ថកិច្ចដទៃទៀតព្រមទាំងអ្នកផ្តល់សេវាត្រូវបានបណ្តុះបណ្តាលនូវចំណេះដឹង និងជំនាញមូលដ្ឋាន ដើម្បីទប់ស្កាត់ កំណត់អត្តសញ្ញាណ បញ្ជូន រាយការណ៍ និងឆ្លើយតបទៅនឹងរាល់គ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា និងការរំលោភបំពានកុមារ ព្រមទាំងការយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ។

5. ក្រសួងនឹងធ្វើការលើកកម្ពស់ឱ្យបានសកម្ម ដើម្បីជម្រុញការចូលរួមរបស់កុមារ ក្នុងការសម្រេចចិត្ត នានា ដែលបង្កឱ្យមានផលប៉ះពាល់លើជីវិតរបស់ពួកគេ ដូចជាការសម្រេចចិត្តអំពីការទុកដាក់នៅក្នុងគ្រួសារ។

6. ក្រសួងនឹងបង្កើត អនុវត្ត និងពង្រឹងក្រមសីលធម៌វិជ្ជាជីវៈស្តីពីកិច្ចការពារកុមារសម្រាប់មន្ត្រីពាក់ព័ន្ធធ្វើការងារលើវិស័យសុខុមាលភាពកុមារ ព្រមទាំងធានាថា មន្ត្រីទាំងនោះបានទទួលការបណ្តុះបណ្តាល និងការប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ។ ក្រសួងនឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសម្របសម្រួលឱ្យមានការអភិវឌ្ឍ និងការត្រួត

ការពារកុមាររបស់យើង នៅកម្ពុជា

ពិនិត្យឡើងវិញទៅលើក្រមសីលធម៌វិជ្ជាជីវៈស្តីពីកិច្ចការពារកុមារ ព្រមទាំងនឹងធានាថា ក្រមសីលធម៌នេះចែងពីទោសប្បញ្ញត្តិសម្រាប់ករណីរំលោភបំពានទៅលើរកុមារ ឬ យេនឌ័រ ជាពិសេសគឺការរំលោភផ្លូវភេទលើកុមារ។

7. ក្រសួងនឹងបង្កើតការវិនិយោគទៅលើប្រព័ន្ធសុខុមាលភាពសង្គម និងប្រព័ន្ធសុខុមាលភាពកុមារទូទៅនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្កលក្ខណៈឱ្យមានការពង្រីក និងការបណ្តុះបណ្តាលបុគ្គលិកសង្គមកិច្ច ព្រមទាំងការបង្កើនថវិកាសម្រាប់សេវាគាំទ្រសង្គមមួយចំនួន ដូចជាកម្មវិធីស្វែងរកគ្រួសារ ការគ្រប់គ្រងករណី កិច្ចគាំទ្រនៅក្នុងនីតិវិធីនគរបាល តុលាការ សេវាសមាហរណកម្ម និងតាមដាន។

8. ដោយមានកិច្ចសហការជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី និងគណៈកម្មការដឹកនាំកិច្ចការសិក្សាស្រាវជ្រាវថ្នាក់ជាតិជុំវិញបញ្ហាអំពើហិង្សាលើកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងសម្របសម្រួលឱ្យមានការអភិវឌ្ឍផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើកុមារ។

9. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងសម្របសម្រួលឱ្យមានការពង្រឹង និងការធ្វើសុខដុមនីយកម្មការឆ្លើយតបរបស់អង្គការមិនមែនរដ្ឋាភិបាល ចំពោះអំពើហិង្សាលើកុមារ ដែលបំពេញបន្ថែមទៅលើការផ្តួចផ្តើមដែលដឹកនាំដោយរាជរដ្ឋាភិបាល ឱ្យស្របតាមរបកគំហើញនៃការសិក្សាស្រាវជ្រាវថ្នាក់ជាតិជុំវិញបញ្ហាអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។

10. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងសម្របសម្រួល ព្រមទាំងលើកកម្ពស់ប្រព័ន្ធប្រមូលទិន្នន័យតាមបណ្តាក្រសួង ស្ថាប័ន និងតួអង្គនានា ដើម្បីឱ្យទទួលបាននូវយន្តការត្រួតពិនិត្យមួយ ដែលងាយស្រួលប្រើប្រាស់សម្រាប់ការងារទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ និងធានាថាទិន្នន័យប្រកបដោយគុណភាពត្រូវបានប្រមូលក្នុងលក្ខណៈជាប្រព័ន្ធ។

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រសួងអប់រំ យុវជន និងកីឡា

## ក្រសួងនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់ និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងនឹងសមាហរណកម្មយុទ្ធសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន និងការធ្វើជាឪពុកម្តាយបែបវិជ្ជមាន ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារនៅក្នុងគ្រួសារទៅក្នុងសេចក្តីណែនាំសម្រាប់ការអប់រំឪពុកម្តាយ អ្នកថែទាំកុមារ និងការបណ្តុះបណ្តាលបុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធក្នុងលក្ខណៈជាផ្នែកមួយនៃការងាររបស់ក្រសួងលើការងារគាំពារ និងអភិវឌ្ឍកុមារតូច។

2. ក្រសួងនឹងសហការជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី និងកំណត់គោលដៅទៅលើកុមារ ក្មេងជំទង់ និងយុវជន តាមរយៈអន្តរាគមន៍ ទាំងក្នុង និងក្រៅសាលារៀន ព្រមទាំងធានាថា សកម្មភាពអប់រំឆ្លើយតបទៅនឹងនិយាមបទដ្ឋាន និងការអនុវត្តយេនឌ័របែបប្រពៃណីវិសមភាពយេនឌ័រការរើសអើងនិងអតុល្យភាពនៃអំណាច។ក្រសួងលើកកម្ពស់និយាមបទដ្ឋាននានាដែលថ្កោលទោសទៅលើការរំលោភសេពសន្ថវៈជាបុគ្គល និងជាក្រុមតាមរយៈការកំណត់គោលដៅទៅលើក្រុមក្មេងជំទង់ និងការប្រើប្រាស់អភិក្រមក្រុមមិត្តភក្តិ។

3. ក្រសួងនឹងពង្រឹងការអនុវត្តច្បាប់ស្តីពីការអប់រំ ព្រមទាំងធានាថា បុគ្គលិកអប់រំគ្រប់រូបបានទទួលការបណ្តុះបណ្តាល និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។ចំណាត់ការខាងវិន័យសម្រាប់បទល្មើសនិងការប្រព្រឹត្តខុសក្រមសីលធម៌វិជ្ជាជីវៈ ជាពិសេសអំពើហិង្សាផ្លូវភេទនឹងត្រូវអនុវត្តចំពោះបុគ្គលិកអប់រំ ដែលប្រព្រឹត្តបទល្មើស ដោយធ្វើការងារជិតស្និទ្ធជាមួយនគរបាល និងវិស័យយុត្តិធម៌។

4. ក្រសួងនឹងជំរុញឱ្យប្រើប្រាស់នូវវិធីសាស្ត្របង្រៀន និងរៀនបែបអហិង្សាសម្រាប់បុគ្គលិកអប់រំ ដើម្បីលុបបំបាត់ទណ្ឌកម្មលើរាងកាយ និងទប់ស្កាត់ការអនុវត្តទណ្ឌកម្មនៅតាមសាលារៀន។

5. ក្រសួងនឹងពង្រឹង និងពង្រីកការអនុវត្តគោលនយោបាយស្តីពីសាលាកុមារមេត្រីសម្រាប់ការអប់រំកម្រិតមូលដ្ឋាន ដោយផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើទិដ្ឋភាពផ្នែក«ការពារ»នៃក្របខ័ណ្ឌនេះព្រមទាំងកម្មវិធីបង្ការបឋមតាមសាលារៀន ដើម្បីធានាថាសាលារៀនពុំមានអំពើហិង្សាគ្រប់ទម្រង់។ កុមារបានរៀន និងយល់ដឹងអំពីការរំលោភបំពាន និយាមបទដ្ឋាននានាដែលថ្កោលទោសទៅលើអំពើហិង្សាគ្រប់ទម្រង់ និងលើកកម្ពស់សមភាពយេនឌ័រ។ គ្រូបង្រៀនអាចកំណត់អត្តសញ្ញាណ និងបង្ហាញករណីអំពើហិង្សាជាក់ស្តែង។ ក្រសួងនឹងលើកកម្ពស់ការចូលរួមរបស់កុមារនៅក្នុងការធ្វើសេចក្តីសម្រេច ដូចជាការគ្រប់គ្រងសាលារៀន និងគុណភាពនៃការអប់រំ។

6. ក្រសួងនឹងបង្កើតឱ្យមានយន្តការបណ្តឹងរាយការណ៍និងបញ្ជូនករណីរំលោភបំពានកុមារប្រកបដោយប្រសិទ្ធភាពស្របតាមកម្មវិធីសាលាកុមារមេត្រី និងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រនៅតាមសាលារៀន ដោយចាត់តាំងគ្រូបង្រៀនឱ្យទទួលបន្ទុកការងារនេះ ដោយធានាការសម្ងាត់របស់សាមីជន និងការសម្របសម្រួល តាមរយៈគណៈគ្រប់គ្រងសាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យមានការថែទាំ ការព្យាបាល និងការតាមដានសមស្របទៅលើករណីរំលោភបំពាន។ ក្រសួងធានាថាកុមារ ជាពិសេសកុមារី មានភាពអង់អាចហ៊ាននិយាយអំពីការរំលោភបំពានសិទ្ធិរបស់ពួកគេ និងរាយការណ៍អំពីករណីអំពើហិង្សា និងការរំលោភបំពានផ្លូវភេទ និងផ្លូវកាយ។

7. ក្រសួងនឹងធានាថាបុគ្គលិកអប់រំដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកការងារនេះ បានទទួលការបំប៉នស្តីពីការណែនាំអំពីកម្មវិធីសាលាកុមារមេត្រី និងការផ្តោតយកចិត្តទុកដាក់ខ្ពស់លើផ្នែកយេនឌ័រ បំណិនប្រឹក្សាបឋម និងសេវាដើម្បីឱ្យមានបរិយាកាសការពារ នៅគ្រប់សាលារៀន។ ក្រសួងនឹងធានាថាបុគ្គលិកអប់រំទាំងនេះទទួលបានចំណេះដឹង និងបំណិនមូលដ្ឋាន ដើម្បីទប់ស្កាត់ កំណត់អត្តសញ្ញាណ បញ្ជូន រាយការណ៍ និងឆ្លើយតបចំពោះអំពើហិង្សាគ្រប់ទម្រង់នៅតាមសាលារៀន។

8. ក្រសួងនឹងបង្កើនការវិនិយោគទៅលើការអប់រំទាំងក្នុងនិងក្រៅប្រព័ន្ធ ជាពិសេសក្របខ័ណ្ឌគោលនយោបាយស្តីពីសាលាកុមារមេត្រី សម្រាប់ការអប់រំកម្រិតមូលដ្ឋាន (សមាសភាគផ្នែកការពារ)។

ការពារ
កុមារ
របស់យើង
នៅកម្ពុជា

# ក្រសួងសុខាភិបាល

## ក្រសួងនឹងអំពាវនាវឲ្យ ពង្រឹងយន្តការ និងវិធានការប្រឆាំងនឹងអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់ និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងនឹងរៀបចំគោលការណ៍ណែនាំគ្លីនិក និងធ្វើការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលស្តីពីការឆ្លើយតបចំពោះអំពើហិង្សាលើកុមាររួមទាំងការកំណត់អត្តសញ្ញាណកុមាររងគ្រោះដោយអំពើហិង្សា ការពិនិត្យ ថែទាំព្យាបាល ការធ្វើរបាយការណ៍ និងការបញ្ជូនករណីអំពើហិង្សាលើកុមារទៅទទួលសេវាសង្គមដែលចាំបាច់ ប្រកបដោយប្រសិទ្ធភាព។ សេវាពិនិត្យថែទាំទាំងនោះរួមបញ្ចូលទាំងការពិគ្រោះយោបល់ ការធ្វើកោសល្យវិច័យ ការព្យាបាល ការបង្ការការចម្លងមេរោគអេដស៍ និងការផ្តល់មធ្យោបាយពន្យារកំណើតបន្ទាន់សម្រាប់កុមារីវ័យជំទង់ ការសង្គ្រោះបន្ទាន់ និងការថែទាំព្យាបាលចាំបាច់ដទៃទៀត ។
2. ក្រសួងនឹងពង្រឹងសកម្មភាពចុះផ្តល់សេវានៅតាមមូលដ្ឋានសហគមន៍ រួមបញ្ចូលទាំងការគាំទ្រ ការអប់រំអំពីការលូតលាស់ទាំងស្មារតី និងរាងកាយរបស់កុមារ បង្កើនការយល់ដឹងអំពីផលប៉ះពាល់នៃអំពើហិង្សា និងការដាក់វិន័យទណ្ឌកម្មដោយហិង្សាលើកុមារ ដើម្បីលើកកម្ពស់ទំនាក់ទំនងរវាងកុមារ និងឪពុកម្តាយ/អ្នកថែទាំរបស់កុមារប្រកបដោយសុវត្ថិភាព ស្នេហភាព និងផ្តល់អំណោយផលដល់ការលូតលាស់របស់កុមារ។
3. ក្រសួងនឹងបន្តពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈដល់គ្រប់បុគ្គលិកសុខាភិបាលទាំងអស់ ដែលកំពុងផ្តល់សេវានៅគ្រប់មូលដ្ឋានសុខាភិបាលដោយផ្តោតលើការផ្តល់សេវាដែលមានលក្ខណៈកុមារមេត្រី (ស្តាប់កុមាររាយការណ៍ និងផ្តល់សេវាដោយគ្មានការរើសអើង គ្មានការចំអក ឬព្រងើយកន្តើយ) មានសុវត្ថិភាព មានឯកជនភាព និងរក្សាការសម្ងាត់។
4. ក្រសួងនឹងធ្វើការអប់រំផ្សព្វផ្សាយអំពីផលប៉ះពាល់ដល់កុមារ និងក្មេងជំទង់ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង និងរៀបចំសេចក្តីព្រាងច្បាប់ហាមឃាត់ការលក់គ្រឿងស្រវឹងឲ្យកុមារ និងមនុស្សវ័យក្មេងអាយុក្រោម២១ឆ្នាំ។
5. ក្រសួងនឹងបញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារទៅក្នុងកម្មវិធី និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ក្រសួង។
6. ក្រសួងនឹងបញ្ចូលទិន្នន័យអំពីការឆ្លើយតបអំពើហិង្សាលើកុមារទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល។

ការពារ
កុមារ
របស់យើង
នៅកម្ពុជា

# ក្រសួងមហាផ្ទៃ

## ក្រសួងនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹង លើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងបាននិងកំពុងបង្កើតកម្មវិធីបង្ការតាមសហគមន៍ព្រមទាំងឲ្យសហគមន៍លើកអំណះអំណាងឆ្លើយតបទៅនឹងនិយាមបទដ្ឋានសង្គម និងវប្បធម៌ដែលលើកកម្ពស់ការទទួលយកអំពើហិង្សាលើកុមារ។ ក្រសួងនឹងបន្តឱ្យមានការចូលរួមពីមន្ត្រីនគរបាលជាតិតាមសហគមន៍ដើម្បីឱ្យដើរតួជាវាគ្មិននៅតាមសាលារៀន សម្រាប់បង្ហាញអំពីតួនាទីរបស់នគរបាល ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាគ្រប់ទម្រង់។

2. ក្រសួងមានបណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ ដែលឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។ ក្រសួងនឹងធានាថាបណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ទាំងនោះបានដំណើរការយ៉ាងពេញលេញ និងស្ថិតក្រោមកិច្ចប្រតិបត្តិការរបស់មន្ត្រីនគរបាលជាតិ (លេខ117 និង 118 សម្រាប់អគ្គស្នងការដ្ឋាននគរបាលជាតិ និងលេខ 023 997 919 និង1288 សម្រាប់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន)។

3. ក្រសួងនឹងធានាថាក្រមសីលធម៌វិជ្ជាជីវៈរបស់នគរបាលជាតិកម្ពុជាមានបញ្ចូលបទដ្ឋានស្ដីពីកិច្ចការពារកុមារ ព្រមទាំងធានាថាមន្ត្រីនគរបាលគ្រប់រូបបានទទួលការបណ្ដុះបណ្ដាល និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ។វិធានការខាងវិន័យចំពោះបទល្មើសនិងការប្រព្រឹត្តខុសក្រមសីលធម៌វិជ្ជាជីវៈជាពិសេសអំពើហិង្សាផ្លូវភេទនឹងត្រូវអនុវត្តចំពោះមន្ត្រីនគរបាលប្រព្រឹត្តបទល្មើសដោយធ្វើការងារជិតស្និទ្ធជាមួយវិស័យយុត្តិធម៌។

4. ក្រសួងនឹងធានាថា ប៉ុស្តិ៍នគរបាលរដ្ឋបាលទាំងអស់គឺជាកន្លែងផ្ដល់នូវសេវា និងភាពកក់ក្ដៅដល់កុមារ ក្នុងការរាយការណ៍ពេលមានករណីកើតមានអំពើហិង្សា និងការរំលោភបំពាន ក្នុងបរិយាកាសមួយដែលរក្សាការសម្ងាត់ និងផ្ដល់កិច្ចគាំទ្រ។ ក្រសួងនឹងធានាថា ការស៊ើបអង្កេតរបស់នគរបាលនឹងស្ថិតក្រោមនីតិវិធីស៊ើបអង្កេតកុមារមេត្រី ដែលមានល័ក្ខខ័ណ្ឌស្របតាមសេចក្ដីត្រូវការជាក់លាក់របស់កុមាររងគ្រោះ។ ប៉ុស្តិ៍នគរបាលរដ្ឋបាលនឹងមានមន្ត្រីនគរបាលជានារី ដែលបានទទួលការបណ្ដុះបណ្ដាលអំពីការសម្ភាសកុមារដោយប្រុងប្រយ័ត្នខ្ពស់។ក្រសួងនឹងលើកកម្ពស់ការចូលរួមរបស់កុមារឱ្យបានច្រើនបំផុតដូចដែលអាចធ្វើទៅបាន នៅក្នុងការធ្វើសេចក្ដីសម្រេចនានា ដែលបង្កឱ្យមានផលប៉ះពាល់ទៅលើជីវិតរស់នៅរបស់ពួកគេ។

5. ក្រសួងនឹងពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាលក្នុងការកំណត់អត្តសញ្ញាណឆ្លើយតបនិងបញ្ជូនករណីអំពើហិង្សាលើកុមារ រាប់បញ្ចូលការកសាងសមត្ថភាព និងការបណ្ដុះបណ្ដាលជំនាញអំពីការគ្រប់គ្រងករណី និងការផ្ដល់ការប្រឹក្សាយោបល់បឋមការធានាឱ្យមានភាពឯកជននិងការរក្សាការសម្ងាត់ការប្រើប្រាស់ពិធីសារជាក់លាក់សម្រាប់កុមារនិងដោះស្រាយយ៉ាងសកម្មចំពោះនិយាមបទដ្ឋានសង្គម វប្បធម៌ទូទៅ ដែលគ្របដណ្ដប់ទៅលើទំនាក់ទំនងរវាងមនុស្សពេញវ័យ និងកុមារ ដែលបង្កឱ្យមានផលប៉ះពាល់ទៅលើរបៀបដែលមន្ត្រីនគរបាលប្រព្រឹត្តចំពោះកុមារ។ ក្រសួងនឹងបង្កើនការជ្រើសរើស តែងតាំងមន្ត្រីនគរបាលជាតិជានារី ដើម្បីធ្វើប្រតិបត្តិការឆ្លើយតបទៅនឹងករណីដែលពាក់ព័ន្ធនឹងកុមារ។

6. ក្រសួងនឹងបង្កើនការស៊ើបអង្កេតក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះមួយឲ្យមានលក្ខណៈប្រតិសកម្មនិងដាក់ចេញនូវយុទ្ធសាស្ត្រនគរបាលផ្សាភ្ជាប់ទំនាក់ទំនងការងារជិតស្និទ្ធជាមួយសហគមន៍។

7. ក្រសួងនឹងពង្រឹងកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហារំលោភបំពានលើកុមារ។ ក្រសួងនឹងពង្រឹងរចនាសម្ព័ន្ធដែលមានស្រាប់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ រាប់បញ្ចូលក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងគណៈកម្មការឃុំ សង្កាត់ទទួលបន្ទុកកិច្ចការនារី និងកុមារដើម្បីធានាថាករណីរំលោភបំពានលើកុមារត្រូវបានរាយការណ៍ និងបញ្ជូនទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ។

ការពារកុមាររបស់យើង នៅកម្ពុជា

8. ក្រសួងនឹងពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយដែលមានស្រាប់ក្នុងការការពារកុមារពីអំពើហិង្សា និងការរំលោភបំពាន។

9. ក្រសួងនឹងស្នើសុំបញ្ចូលខ្ទង់ថវិកាសម្រាប់កិច្ចការពារកុមារនៅក្នុងផែនការវិនិយោគ និងផែនការអភិវឌ្ឍន៍របស់ឃុំសង្កាត់។

10. ក្រសួងនឹងគាំទ្រដល់ការសម្របសម្រួលឱ្យមានការពង្រឹង និងការធ្វើសុខដុមនីយកម្មការឆ្លើយតបរបស់អង្គការមិនមែនរដ្ឋាភិបាល ចំពោះអំពើហិង្សាលើកុមារ ដែលបំពេញបន្ថែមទៅលើការផ្តួចផ្តើមដែលដឹកនាំដោយរាជរដ្ឋាភិបាល និងដែលស្របតាមរបកគំហើញនៃការសិក្សាស្រាវជ្រាវថ្នាក់ជាតិជុំវិញបញ្ហាអំពើហិង្សាលើកុមារ ក្នុងប្រទេសកម្ពុជា។

11. ក្រសួងនឹងផ្តល់សិទ្ធិអំណាចដល់អាជ្ញាធមូលដ្ឋានឱ្យរាយការណ៍អំពីករណីអំពើហិង្សាលើស្ត្រី និងកុមារក្រោមគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។ ក្រសួងនឹងបញ្ចូលសូចនាករត្រួតពិនិត្យអំពើហិង្សាលើកុមារ ទៅក្នុងមូលដ្ឋានទិន្នន័យឃុំ សង្កាត់។

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រសួងយុត្តិធម៌

## ក្រសួងនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងយុត្តិធម៌នឹងបន្តខិតខំពង្រឹងសមត្ថភាពជំនាញផ្នែកច្បាប់ក្រមសីលធម៌ដល់មន្ត្រីអនុវត្តច្បាប់ដើម្បីធានានូវកិច្ចការពារកុមារ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ។
2. ក្រសួងយុត្តិធម៌នឹងមានវិធានការណ៍យ៉ាងតឹងរ៉ឹងទៅតាមផ្លូវច្បាប់ចំពោះមន្ត្រីអនុវត្តច្បាប់ ដែលប្រព្រឹត្តខុសនឹងច្បាប់ក្រមសីលធម៌ និងលុបបំបាត់និទណ្ឌភាព។
3. ក្រសួងយុត្តិធម៌នឹងខិតខំជម្រុញឲ្យតុលាការអនុវត្តនីតិវិធីកុមារមេត្រី ក្នុងដំណើរការដោះស្រាយរឿងក្តីកុមារ និងជម្រុញការដោះស្រាយរឿងក្តីកុមារឲ្យបានឆាប់រហ័ស។
4. ក្រសួងក្រសួងយុត្តិធម៌នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់សេវាផ្នែកច្បាប់ និងសេវាសង្គមដល់កុមារដើម្បីធានាការការពារស្របច្បាប់របស់កុមារ។
5. ក្រសួងយុត្តិធម៌នឹងបន្តពិនិត្យពិច័យទៅលើបទបញ្ញត្តិនៃច្បាប់ជាតិ និងបន្តរៀបចំបទបញ្ញត្តិថ្មីៗបន្ថែមទៀតឲ្យស្របតាមនិយាម និងស្តង់ដារអន្តរជាតិ។
6. ក្រសួងយុត្តិធម៌នឹងបន្តពង្រឹងការបណ្តុះបណ្តាល ការតាមដានទាក់ទងនឹងការចុះបញ្ជីរឿងក្តី ដើម្បីពង្រឹងប្រសិទ្ធភាពនៃការចុះបញ្ជី និងតាមដានអំពីចំណាត់ការនៃការដោះស្រាយរឿងក្តី ចាប់តាំងពីដំណាក់កាលដំបូងរហូតដល់បញ្ចប់នីតិវិធី។
7. ក្រសួងយុត្តិធម៌នឹងខិតខំប្រមូលទិន្នន័យកុមារទំនាស់នឹងច្បាប់និងកុមាររងគ្រោះដើម្បីងាយស្រួលក្នុងការតាមដានស្វែងរកតើមានការកើនឡើង ឬថយចុះចំពោះកុមារជាជនរងគ្រោះ កុមារជាជនល្មើស និងកុមារជាជនល្មើសដើម្បីរិះរកវិធានការណ៍ដោះស្រាយ។

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ក្រសួងនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹង លើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងនឹងពង្រឹងកិច្ចខិតខំរបស់ខ្លួនដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមកុមារ ដែលកំពុងធ្វើពលកម្ម អំពីយន្តការរាយការណ៍ទាក់ទងនឹងអំពើហិង្សា និងការរំលោភបំពានទាំងនៅសាលារៀនកន្លែងធ្វើការ និងសហគមន៍ដែលកុមាររស់នៅ។

2. ក្រសួងនឹងបន្តពង្រឹងសមត្ថភាពបុគ្គលិក និងមន្ត្រីអធិការកិច្ចពលកម្មកុមារ ដើម្បីកំណត់អត្តសញ្ញាណ ផ្តល់ការឆ្លើយតបរាយការណ៍ និងបញ្ជូនករណីពលកម្មកុមារប្រកបដោយប្រសិទ្ធភាព លើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយជូនដល់អ្នកពាក់ព័ន្ធអំពីសិទ្ធិកុមារ ច្បាប់ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធនឹងការផ្តល់ការងារជូនដល់កុមារ។ ក្រសួងនឹងបន្តកិច្ចខំប្រឹងប្រែងក្នុងការរួមចំណែកក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ហើយធានាថាមន្ត្រីអធិការកិច្ចពលកម្មកុមារនឹងត្រូវបានបណ្តុះបណ្តាលសម្រាប់ដោះស្រាយចំពោះតែករណីពលកម្មកុមារប៉ុណ្ណោះ។

3. ក្រសួងនឹងពង្រឹងប្រព័ន្ធអធិការកិច្ច ប្រព័ន្ធអនុវត្តច្បាប់ និងប្រព័ន្ធត្រួតពិនិត្យ តាមដានពលកម្មកុមារទាំងអស់ក្នុងវិស័យសេដ្ឋកិច្ចរៀបរយ និងវិស័យសេដ្ឋកិច្ចមិនរៀបរយលើសុវត្ថិភាពការងារដល់កុមារ ដែលកំពុងធ្វើការ។ ក្រសួងនឹងពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិនានាដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន្យពាក់ព័ន្ធនឹងពលកម្មកុមារ។

4. ក្រសួងនឹងពង្រឹងព្រមទាំងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈស្តីពីកិច្ចការពារកុមារសម្រាប់បុគ្គលិក និងមន្ត្រីអធិការកិច្ចការងារ។ ក្រសួងនឹងធានាថាបុគ្គលិក និងមន្ត្រីអធិការកិច្ចការងារបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងនឹងចាត់វិធានការខាងវិន័យសម្រាប់បទល្មើស និងការប្រព្រឹត្តខុសពីក្រមសីលធម៌វិជ្ជាជីវៈ។

5. ក្រសួងនឹងបន្តអនុវត្តនីតិវិធីកុមារមេត្រីនៅក្នុងអធិការកិច្ចការងារ ក្នុងការជួយសង្គ្រោះ និងធ្វើសមាហរណកម្មកុមារទៅក្នុងសង្គម។ ក្រសួងនឹងបន្តភាពជាដៃគូជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា ដើម្បីដកហូតទប់ស្កាត់ និងធ្វើសមាហរណកម្មកុមារ ដែលកំពុងធ្វើពលកម្ម និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារទៅក្នុងសង្គមជាតិវិញ។

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រសួងទេសចរណ៍

## ក្រសួងនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងនឹងបង្កើតប្រព័ន្ធ «ឃ្លាំមើលសហគមន៍» ដើម្បីប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារព្រមទាំងបណ្តុះបណ្តាលរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីតួនាទីរបស់ពួកគេក្នុងការត្រួតពិនិត្យសហគមន៍។

2. ក្រសួងនឹងបន្តពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការលើកកម្ពស់ការយល់ដឹង នៅក្នុងចំណោមកុមារ និងក្មេងជំទង់ព្រមទាំងឪពុកម្តាយ និងអ្នកថែទាំរបស់ពួកគេ អំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងបណ្តាញរាយការណ៍សម្រាប់ឧបទ្ទវហេតុអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច។

3. ក្រសួងនឹងសម្របសម្រួលការអនុវត្តយុទ្ធនាការព័ត៌មាន និងទំនាក់ទំនងគ្រប់ជ្រុងជ្រោយមួយ នៅតាមអាជីវកម្មសេវាកម្មទេសចរណ៍ ដោយកំណត់គោលដៅទៅលើកុមារ និងគ្រួសាររបស់ពួកគេ ព្រមទាំងភ្ញៀវទេសចរជាតិ និងអន្តរជាតិដើម្បីផ្តល់ភាពអង់អាចដល់ពួកគេក្នុងការរាយការណ៍អំពីឧបទ្ទវហេតុនៃអំពើហិង្សា និងការរំលោភបំពាន។ ក្រសួងនឹងបន្តលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលទាក់ទងទៅនឹងការជួញដូរ និងពលកម្មកុមារ នៅក្នុងអាជីវកម្មសេវាកម្មទាំងនេះ។

4. ក្រសួងនឹងអនុវត្ត និងពង្រឹងក្រមសីលធម៌វិជ្ជាជីវៈស្តីពីកិច្ចការពារកុមារ សម្រាប់អភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា។ ក្រសួងនឹងធានាថាគ្រប់សេវាកកម្ម អាជីវកម្ម ឧស្សាហកម្មទេសចរណ៍ទាំងអស់នឹងបានទទួលការបណ្តុះបណ្តាល និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងនឹងចាត់វិធានការរដ្ឋបាលខាងវិន័យសម្រាប់បទល្មើស និងការប្រព្រឹត្តខុសក្រមសីលធម៌ ជាពិសេសអំពើហិង្សាផ្លូវភេទទៅលើបុគ្គលិកប្រព្រឹត្តបទល្មើស ដោយធ្វើការងារជិតស្និទ្ធជាមួយនគរបាល និងវិស័យយុត្តិធម៌។

5. ក្រសួងនឹងកសាងសមត្ថភាពមន្ត្រីនៅកម្រិតថ្នាក់ក្រោមជាតិអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ លើកកម្ពស់ការយល់ដឹងនិងការផ្សព្វផ្សាយជូនដល់អ្នកពាក់ព័ន្ធនានាអំពីសិទ្ធិកុមារនិងច្បាប់ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធទៅនឹងការជួញដូរ និងពលកម្មកុមារ។

6. ក្រសួងនឹងបន្តធ្វើអធិការកិច្ច អនុវត្ត និងត្រួតពិនិត្យគ្រឹះស្ថានទេសចរណ៍ទាំងនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធអំពីល័ក្ខខ័ណ្ឌ និងការអនុវត្តសុវត្ថិភាពកុមារ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ស្តីពីទេសចរណ៍។ ការត្រួតពិនិត្យ និងអធិការកិច្ចនឹងត្រូវអនុវត្តក្រោមនីតិវិធីកុមារមេត្រី។

7. ក្រសួងនឹងបង្កើតយន្តការសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងទីភ្នាក់ងារគាំទ្រជនរងគ្រោះដើម្បីបញ្ជូនកុមាររងគ្រោះពីអំពើជួញដូរ ឬអំពើកេងប្រវ័ញ្ចលើកុមារនៅក្នុងវិស័យទេសចរណ៍។

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រសួងព័ត៌មាន

## ក្រសួងនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងនឹងសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រផ្លាស់ប្តូរការប្រព្រឹត្ត និងយុទ្ធសាស្ត្រផ្លាស់ប្តូរសង្គមពហុវិស័យគ្រប់ជ្រុងជ្រោយមួយ ដើម្បីដោះស្រាយនិយាមបទដ្ឋានសង្គម និងវប្បធម៌ ដែលផ្តល់ធម្មានរូប និងលើកកម្ពស់អំពើហិង្សាលើកុមារ ដោយកំណត់គោលដៅទៅលើតួអង្គសំខាន់ៗនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានចំពោះការគិត ឥរិយាបថ និងការអនុវត្ត។ នេះនឹងបង្កើនលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការកំណត់អត្តសញ្ញាណអំពើហិង្សាលើកុមារ និងការលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមានរបស់វា។

2. ក្រសួងព័ត៌មាននឹងធ្វើការការពារកុមារពីព័ត៌មានដែលបង្កគ្រោះថ្នាក់ដល់កុមារជាពិសេស ព័ត៌មានពីកម្មវិធីទូរទស្សន៍ខ្សែភាពយន្ត ដែលរួមមានអំពើហិង្សាកាចសាហាវ និងរូបភាពអាសអាភាស ព្រមទាំងធានាឱ្យពួកគេមានលទ្ធភាពទទួលបានព័ត៌មានសមស្រប។

3. ក្រសួងនឹងពង្រឹងកិច្ចខិតខំរបស់ខ្លួនដើម្បីបង្ក្រាប និងទប់ស្កាត់ការផ្សព្វផ្សាយរូបភាពអាសអាភាសស្ត្រី និងកុមារ តាមប្រព័ន្ធអេឡិចត្រូនិក។

4. ដោយមានកិច្ចសហការជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក្រសួងនឹងសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងមួយនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ទំនាក់ទំនងដែលមានស្នេហភាព សុវត្ថិភាព និងអំណោយផលដល់ការលូតលាស់របស់កុមាររវាងឪពុកម្តាយ និងកូនរបស់ពួកគេ ដោយអំពាវនាវឱ្យមិនអធ្យាស្រ័យចំពោះទណ្ឌកម្មលើរាងកាយ។

5. ដោយមានកិច្ចសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងនឹងសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងគ្រប់ជ្រុងជ្រោយមួយនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ កំណត់គោលដៅទៅលើកុមារ និងគ្រួសាររបស់ពួកគេ ដើម្បីផ្តល់ភាពអង់អាចដល់ពួកគេក្នុងការរាយការណ៍អំពីឧបទ្ទវហេតុនៃអំពើហិង្សា និងការរំលោភបំពាន។

6. ក្រសួងនឹងធ្វើឲ្យប្រសើរឡើងនូវការឆ្លើយតបពីប្រព័ន្ធផ្សព្វផ្សាយទៅនឹងបញ្ហាអំពើហិង្សាលើកុមារ និងការរាយការណ៍អំពីអំពើហិង្សាលើកុមារតាមរយៈការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងក្រមសីលធម៌ប្រព័ន្ធផ្សព្វផ្សាយមួយ ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាតិមួយចំនួនដូចជា ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

7. ក្រសួងព័ត៌មានបង្កើតវគ្គបណ្តុះបណ្តាលទាំងថ្នាក់ជាតិ និងក្រោមជាតិដែលពាក់ព័ន្ធនឹងក្រមសីលធម៌របស់ប្រព័ន្ធផ្សព្វផ្សាយ។

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រសួងធម្មការ និងសាសនា

## ក្រសួងនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងនឹងជម្រុញឲ្យមានសីលធម៌ វិន័យសាសនា ចំពោះមេដឹកនាំសាសនាទាំងឡាយនៅក្នុងប្រទេសកម្ពុជារួមមានបទដ្ឋានស្តីពីកិច្ចការពារកុមារ ព្រមទាំងជម្រុញឲ្យ មេដឹកនាំសាសនាទាំងនោះ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ វិន័យសាសនារបស់ខ្លួន ជាពិសេសការរំលោភបំពានផ្លូវភេទ ដោយសហការជាមួយស្ថាប័នយុត្តិធម៌។
2. ក្រសួងនឹងបង្កើតឱ្យមានការយល់ដឹងនៅក្នុងសហគមន៍សាសនា តាមរយៈអនុសំវច្ឆរៈ មហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសប្រចាំឆ្នាំ កម្មវិធីសិក្សារបស់សាលាពុទ្ធកសិក្សា នាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម វគ្គបណ្តុះបណ្តាលក្រមសីលធម៌អាចារ្យ អាចារិនីខ្មែរ កិច្ចប្រជុំ ឬសិក្ខាសាលានានា និងទិវាជាតិបួងសួងដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ អំពីផលប៉ះពាល់នៃគ្រប់ទម្រង់នៃអំពើហិង្សាលើកុមារ។
3. មេដឹកនាំសាសនាទាំងឡាយនឹងលើកកម្ពស់សិទ្ធិកុមារ សេចក្តីថ្លៃថ្នូរ និងប្រើប្រាស់ការប្រៀនប្រដៅសាសនាដើម្បីផ្តល់ឧទាហរណ៍ល្អៗ ព្រមទាំងលើកឡើងនូវអំណះអំណាងសម្រាប់ឆ្លើយតបទៅនឹងនិយាមបទដ្ឋាន ឬបទបញ្ញត្តិសាសនាដែលលើកកម្ពស់សកម្មភាពទប់ស្កាត់អំពើហិង្សាលើកុមារ។
4. មេដឹកនាំសាសនាទាំងឡាយធ្វើការប្តេជ្ញាធ្វើសកម្មភាពអប់រំផ្សព្វផ្សាយធម៌វិន័យសាសនា ដើម្បីទប់ស្កាត់អំពើហិង្សាលើផ្លូវកាយ និងផ្លូវចិត្តចំពោះកុមារ ព្រមទាំងលើកកម្ពស់ទម្រង់នៃការប្រណិបត្តិវិន័យសាសនាចំពោះកុមារ ដោយអហិង្សា (អហិង្សាធម៌) នៅក្នុងការអប់រំកុមារ ដើម្បីធានាឱ្យមានទំនាក់ទំនងប្រកបដោយស្នេហភាព មានសុវត្ថិភាព និងអំណោយផលដល់ការលូតលាស់របស់កុមារ រវាងឪពុកម្តាយ អ្នកថែទាំ និងកូនៗរបស់ពួកគេ។
5. មេដឹកនាំសាសនាទាំងឡាយនឹងលើកកម្ពស់ការយល់ដឹង អំពីផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់នៃល្បែងស៊ីសង គ្រឿងញៀន និងគ្រឿងស្រវឹងជាដើម ក្នុងចំណោមឪពុកម្តាយ អ្នកថែទាំ កុមារ និងយុវវ័យ ដោយធ្វើការលើកកម្ពស់យ៉ាងសកម្ម ដើម្បីឱ្យមានការប្រព្រឹត្តវិជ្ជមាន(សុចរិតភាព)។
6. ក្រសួងនឹងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរសាសនា ដោយធ្វើការចែករំលែកបទពិសោធ និងការអនុវត្តនានា ក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ តាមរយៈសិក្ខាសាលា ឬកិច្ចប្រជុំប្រចាំខែ ប្រចាំឆ្នាំជាដើម។

ការពារកុមាររបស់យើង
នៅកម្ពុជា

# វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

## ក្រសួងនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រសួងនឹងរួមចំណែកចំពោះការវាយតម្លៃទៅលើចំណាត់ការទប់ស្កាត់ និងឆ្លើយតបជាក់លាក់ ដែលជាផ្នែកមួយនៃផែនការសកម្មភាពជាតិស្ដីពីការបង្ការ និងការឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ក្នុងគោលបំណងវាស់វែងទៅលើផលប៉ះពាល់នៃចំណាត់ការទាំងនោះ និងធានាថាចំណាត់ការទាំងនោះមានភាពប្រសើរឡើងជាបន្តបន្ទាប់។

2. ក្រសួងនឹងបន្តសហការជាមួយក្រសួងកិច្ចការនារីធ្វើការអង្កេតស្ដីពីអំពើហិង្សាលើកុមារជាប្រចាំ ដើម្បីតាមដានទៅលើនិន្នាការប្រែប្រួល និងវិធានការដែលមានការវិវត្ត។

3. ក្រសួងនឹងបន្តសហការជាមួយក្រសួងកិច្ចការនារីធ្វើការវិភាគទិន្នន័យដែលទទួលបានពីការអង្កេតទាំងនេះ ដើម្បីបង្ហាញអំពីរបកគំហើញនានា ដែលអាចជាមូលដ្ឋានសម្រាប់រៀបចំយុទ្ធសាស្រ្តបង្ការ និងគោលនយោបាយសាធារណៈ ដោយមានការបំពេញបន្ថែមពីការស្រាវជ្រាវបែបគុណភាព ដើម្បីសម្រួចការយល់ដឹងអំពីបរិបទនៃអំពើហិង្សាលើកុមារ។

4. ក្រសួងនឹងបន្តសហការជាមួយក្រសួងកិច្ចការនារី ធ្វើការស្រាវជ្រាវបន្តទៀតអំពីអំពើហិង្សាលើកុមារដែលរស់នៅក្រៅផ្ទះ កុមារពិការ កុមារផ្ទុកមេរោគអេដស៍ ព្រមទាំងទម្រង់ដទៃទៀតនៃអំពើហិង្សា ដែលមិនត្រូវបានគ្របដណ្ដប់នៅក្នុងការសិក្សាស្រាវជ្រាវថ្នាក់ជាតិជុំវិញបញ្ហាអំពើហិង្សាលើកុមារ។

5. ក្រសួងនឹងសម្របសម្រួលឱ្យមានការបង្កើតយន្តការសមាហរណកម្មទិន្នន័យនិងត្រួតពិនិត្យដើម្បីរាយការណ៍អំពីសមិទ្ធផលដែលសម្រេចបាន ចំពោះផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ។

ការពារកុមាររបស់យើង នៅកម្ពុជា

# ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីអនុសញ្ញាស្តីពីសិទ្ធិកុមារដល់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី និងសហគមន៍ ពិសេសផ្តោតការយកចិត្តទុកដាក់ចំពោះក្រុមជនជាតិភាគតិច នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។

2. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងកសាងភាពធន់មាំ របស់កុមារចំពោះអំពើហិង្សាព្រមទាំងលើកកម្ពស់ការចូលរួមរបស់កុមារនៅក្នុងការរាយការណ៍ទាំងឡាយណាដែលទាក់ទងទៅនឹងសិទ្ធិកុមារ។

3. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការលើកកម្ពស់ការយល់ដឹងដល់កុមារ គ្រួសារ សហគមន៍ និងអ្នកដែលធ្វើការងារផ្ទាល់ជាមួយកុមារអំពីច្បាប់ និងគោលនយោបាយពាក់ព័ន្ធដែលការពារកុមារពីអំពើហិង្សា និងការរំលោភបំពាន ដោយលើកកម្ពស់ការយល់ដឹងអំពីទោសទណ្ឌនៃទង្វើ។

4. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នឹងផ្សព្វផ្សាយអំពីការវិភាគភាពខ្វះចន្លោះនៃក្របខ័ណ្ឌច្បាប់ការការពារកុមារនៅព្រះរាជាណាចក្រកម្ពុជា ផ្អែកលើការត្រួតពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងអភិវឌ្ឍយុទ្ធសាស្ត្រស្វែងរកការគាំទ្រមតិថ្មីមួយ ជាមួយនឹងអនុសាសន៍សម្រាប់ធ្វើវិសោធនកម្ម ឬរៀបចំធ្វើច្បាប់ថ្មី សម្រាប់បង្ហាញជូនទៅស្ថាប័នសមស្រប។

5. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងធ្វើការស្វែងរកការគាំទ្រមតិយ៉ាងសកម្ម ដើម្បីបង្កើនការវិនិយោគ សំដៅដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ នៅក្នុងចំណោមសមាជិកទាំងអស់របស់ខ្លួន។

6. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងបង្កើតយន្តការប្រមូលទិន្នន័យ និងពិនិត្យតាមដានដើម្បីផ្តល់របាយការណ៍ប្រចាំឆ្នាំអំពីសមិទ្ធផលដែលសម្រេចបាន លើការអនុវត្តផែនការសកម្មភាពជាតិដើម្បីកុមារ។

ការពារកុមាររបស់យើង
នៅកម្ពុជា

# អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍

## អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍នឹងអំពាវនាវ មិនឲ្យអធ្យាស្រ័យចំពោះអំពើហិង្សាលើកុមារ ព្រមទាំងនឹងលើកកម្ពស់និយាមបទដ្ឋានសង្គម ដែលថ្កោលទោសអំពើហិង្សាគ្រប់ទម្រង់

1. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងបញ្ជ្រាប និងបញ្ចូលភាពមិនអាចអត់អោនឲ្យបាននូវ អំពើហិង្សាប្រឆាំងនឹងកុមារទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិបីសូន្យ ក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

2. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងតាក់តែង ផលិត និងចែកចាយនូវធនធានអប់រំគ្រប់ប្រភេទ និងគ្រប់រូបភាពសម្រាប់កុមារក្នុងការយល់ដឹងដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងការប្រឈមមុខនឹងគ្រោះថ្នាក់នៃអំពើហិង្សាដែលទាក់ទងនឹងការចម្លងមេរោគអេដស៍។

3. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងធ្វើសហការណ៍ជាមួយក្រសួងសុខាភិបាល ក្នុងការធានាឲ្យមាននូវសេវាចាំបាច់សម្រាប់កុមាររងគ្រោះដោយអំពើហិង្សា និងមេរោគអេដស៍ និងជំងឺអេដស៍ (សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសម្ងាត់ សេវារំលូតកូន សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន សេវាពន្យារកំណើត សេវាព្យាបាលជំងឺកាមរោគ)។

4. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងតាមដាន និងវាយតម្លៃស្វែងយល់ពីវឌ្ឍនៈភាព ប្រសិទ្ធភាព និងសមិទ្ធផលស្តីពីការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមកុមារប្រឈមមុខ និងរងគ្រោះដោយអំពើហិង្សា។

ការពារកុមាររបស់យើង នៅកម្ពុជា

ក្រសួងកិច្ចការនារី

unicef

unite for children